**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..០៨..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទ ដើម្បីធ្វើការលើកលែងទោសស្ត្រីមានគភ៌និងមានកូនដែលជាប់ពន្ធនាគារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគភ៌និងមានកូនដែលជាប់ពន្ធនាគារ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៣- ឯកឧត្តម នុត សាអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម ស៊ូ ភិរិន្ទ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក។ |

**ប្រការ ២.-**

ក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគភ៌និងមានកូនដែលជាប់ពន្ធនាគារ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ពិនិត្យ ស្រាវជ្រាវ ផ្ទៀងផ្ទាត់ស្ថិតិ និងរៀបចំបែបបទ ដើម្បីធ្វើការលើកលែងជនជាប់ឃុំជាស្ត្រីមានគភ៌ និងមានកូនដែលជាប់ពន្ធនាគារ
- សហការជាមួយស្ថាប័នតុលាការដើម្បីជំរុញការងារស្រង់ និងផ្ទៀងផ្ទាត់ស្ថិតិជនជាប់ឃុំជាស្ត្រីមានគភ៌ និងមានកូនដែលជាប់ពន្ធនាគារ
- លើកសំណើលើការលែងទោសស្ត្រីមានគភ៌និងមានកូនដែលជាប់ពន្ធនាគារ ជូនប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគភ៌និងមានកូនដែលជាប់ពន្ធនាគារ អាចបង្កើតក្រុមជំនាញមួយចំនួនតាមការចាំបាច់។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ